# ការស្ទង់មតិ៖ សេរីភាពមូលដ្ឋានថ្នាក់ដឹកនាំនៃអង្គការសង្គមស៊ីវិល និងសហជីព មានភាពប្រសើរជាងមុន




*(រូបភាពតំណាងសហជីព) សកម្មភាពបញ្ចេញសេរីភាពរបស់កម្មករ កម្មការនីរោងចក្រ Y&W ក្នុងការទាមទារដំណោះស្រាយ។*

ភ្នំពេញ៖ ការស្ទង់មតិដែលចេញដោយអង្គការសិទ្ធិមនុស្សចំនួន៣ បង្ហាញថាក្នុងរយៈពេល ៨ឆ្នាំ ដោយរាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២៣ បង្ហាញថា ក្នុងឆ្នាំ២០២៣ សេរីភាពមូលដ្ឋានដែលថ្នាក់ដឹកនាំសង្គមស៊ីវិល និងសហជីពទទួលបានមានលក្ខណៈល្អប្រសើរជាងឆ្នាំកន្លងៗទៅ។

របាយការណ៍នៃការស្ទង់មតិដែលរៀបចំឡើងដោយក្រុមអង្គការ ធ្វើការលើវិស័យសិទ្ធិមនុស្សចំនួន៣រួមមាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR) សមាគមសិទ្ធិមនុស្សអាដហុក និង SOLIDARITY CENTER បង្ហាញឱ្យឃើញថា ការអភិវឌ្ឍវិជ្ជមាននៃសិទ្ធិសេរីភាពមូលដ្ឋានមកដល់ឆ្នាំ២០២៣ ដោយគិតតាំងពីឆ្នាំ២០១៦ មានការអភិវឌ្ឍវិជ្ជមាន។ វិជ្ជមានព្រោះថា ការឆ្លើយតបរបស់ថ្នាក់ដឹកនាំសង្គមស៊ីវិល

និងសហជីពថា ក្នុងឆ្នាំ២០២៣ ការតាមឃ្លាំមើលដ៏រឹតត្បិតរបស់រដ្ឋាភិបាលថយចុះចំនួន ៦ភាគរយ ពោលពី៦៤ភាគរយក្នុងឆ្នាំ២០២២ មកនៅ៥៨ភាគរយក្នុងឆ្នាំ២០២៣។

ខ្លឹមសារនៃរបាយការណ៍ឱ្យដឹងបន្ថែមថា ទន្ទឹមនឹងការឃ្លាំមើលពីសំណាក់រដ្ឋាភិបាលទៅលើសង្គមស៊ីវិលធ្លាក់ចុះ ក្នុងនោះបណ្ដាអ្នកដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ១៥០នាក់ មើលឃើញថាខ្លួនត្រូវបានរដ្ឋាភិបាលទទួលស្គាល់ជាដៃគូរអភិវឌ្ឍន៍ស្របច្បាប់មានការកើនឡើងក្នុងឆ្នាំ២០២៣ បើធៀបនឹងឆ្នាំកន្លង។

បើក្រឡេកទៅមើលការភ័យខ្លាចពីសុវត្ថិភាពក្នុងការបញ្ចេញទស្សនៈតាមរយៈប្រព័ន្ធផ្សព្វផ្សាយវិញក៏ផ្ដល់នូវលទ្ធផលវិជ្ជមានផងដែរ ពោលមានលក្ខណៈប្រសើរឡើងនៅឆ្នាំ២០២៣ដូចគ្នា។ ចំណុចនេះបង្កឱ្យអ្នកចងក្រងរបាយការណ៍សម្ដែងការភ្ញាក់ផ្អើល ខណៈដែលខ្លួនឃើញថា អារម្មណ៍ដែលថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពមិនមានសុវត្ថិភាពក្នុងការបញ្ចេញមតិយោបល់តាមប្រព័ន្ធផ្សព្វផ្សាយនោះមានការថយចុះ ១៦ភាគរយ។ នេះជាភាគរយតិចបំផុតចាប់តាំងពីការចាប់ផ្ដើមកត់ត្រារបស់គម្រោងក្នុងឆ្នាំ២០១៦មក។

បើទោះបីជាការស្ទង់មតិទាំងនេះរកឃើញនូវភាពវិជ្ជមាននូវចំណុចមួយចំនួនបែបនេះក្ដី ក៏ប៉ុន្តែគេនៅតែមើលឃើញថាមានភាពអវិជ្ជមានដែលនៅតែបន្តកើតមាន ហើយទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមផងដែរ។ក្នុងនោះពាក់ព័ន្ធទៅនឹងសិទ្ធិមួយចំនួនដែលសង្គមស៊ីវិលគួរត្រូវបានលើកទឹកចិត្តឱ្យមានវត្តមាន ដោយតម្រូវឱ្យមានការជជែកពិភាក្សា តែពួកគេបែរជាគ្មានវត្តមានចូលរួមទៅវិញ។ ជាក់ស្ដែងអង្គការសង្គមស៊ីវិលនៅតែត្រូវបានផាត់ចេញពីការជជែកពិភាក្សានៅក្នុងការតាក់តែងច្បាប់ការធ្វើវិសោធនកម្មច្បាប់បោះឆ្នោតដែលបានអនុម័តក្នុងខែកក្កដា ឆ្នាំ២០២៣ ដោយគ្មានការពិភាក្សា៕